# វិធីដើម្បីទទួលបានមធ្យោបាយធ្វើដំណើរទៅកាន់ការណាត់ជួបទទួលវ៉ាក់សាំង COVID-19 របស់អ្នក

## ទិដ្ឋភាពទូទៅ

ប្រសិនបើអ្នកមាន Apple Health (Medicaid) ហើយត្រូវការជំនួយដើម្បីទៅកាន់ការណាត់ជួបថែទាំសុខភាពរបស់អ្នកនោះ Health Care Authority (HCA, អាជ្ញាធរថែទាំសុខភាព) នឹងរ៉ាប់រងលើមធ្យោបាយធ្វើដំណើររបស់អ្នក។ អ្នកអាចប្រើសេវាកម្មនេះសម្រាប់ការណាត់ជួបវេជ្ជសាស្ត្រដែលមិនបន្ទាន់ដូចជាការទទួលការចាក់វ៉ាក់សាំង COVID-19។

## របៀបក្នុងការទទួលបានជំនួយផ្នែកមធ្យោបាយធ្វើដំណើរ

ហៅទូរសព្ទទៅឈ្មួញកណ្ដាលផ្នែកមធ្យោបាយធ្វើដំណើរក្នុងខោនធីរបស់អ្នក (មើលបញ្ជីលេខទូរសព្ទឈ្មួញកណ្ដាលនៅទំព័រទី 2)។ ឈ្មួញកណ្ដាលនឹងពិនិត្យមើលសិទ្ធិទទួលបានរបស់អ្នក និងរៀបចំមធ្យោបាយធ្វើដំណើរដែលសមស្របនឹងតម្រូវការចល័តរបស់អ្នក។ ប្រសិនបើអ្នកមិនមានសិទ្ធិទទួលបានសេវាកម្មនេះទេ ឈ្មួញកណ្ដាលនឹងនាំអ្នកទៅធនធានក្នុងតំបន់ផ្សេងទៀត។

សូមត្រៀមព័ត៌មានខាងក្រោមឲ្យបានរួចរាល់នៅពេលអ្នកទូរសព្ទទៅ៖

- ប័ណ្ណសេវាកម្ម ProviderOne របស់អ្នក
- អាសយដ្ឋានទៅយកពេញលេញរបស់អ្នក
- ទីតាំងណាត់ជួបទទួលវ៉ាក់សាំងរបស់អ្នក
- ឈ្មោះ និងលេខទូរសព្ទរបស់អ្នកផ្តល់សេវាវេជ្ជសាស្ត្ររបស់អ្នក (អ្នកមិនត្រូវការព័ត៌មាននេះទេ ប្រសិនបើអ្នកត្រូវការមធ្យោបាយធ្វើដំណើរទៅកន្លែងផ្តល់វ៉ាក់សាំង COVID-19 ទ្រង់ទ្រាយធំ)
- កាលបរិច្ឆេទ និងពេលវេលាណាត់ជួបជាក់លាក់របស់អ្នក
- ប្រភេទនៃការណាត់ជួបថែទាំសុខភាព (ឧទាហរណ៍ដូចជាការណាត់ជួបសម្រាប់ការលាងឈាម OB ទន្តិក ការទទួលវ៉ាក់សាំង COVID-19 ។ល។)

## សំណួរចោទសួរជាញឹកញាប់

**អ្វីជាមធ្យោបាយធ្វើដំណើរវេជ្ជសាស្ត្រដែលមិនបន្ទាន់?**
នេះគឺជាសេវាកម្មដែលអាចជួយជូនអ្នកទៅកាន់ និងត្រឡប់ពីការណាត់ជួបថែទាំសុខភាពរបស់អ្នក។ ប្រភេទនៃមធ្យោបាយធ្វើដំណើរទូទៅភាគច្រើន រួមមានឡានក្រុងសាធារណៈ តាក់ស៊ី រថយន្តដឹកអ្នកដំណើរខ្នាតតូចសម្រាប់រទេះរុញ សក្ខីប័ត្រសាំង និងសំណងតាមចម្ងាយគិតជាម៉ៃល៍។ សេវាកម្មនេះមិនរាប់បញ្ចូលគ្រែសែងអ្នកជំងឺ រថយន្តសង្គ្រោះបន្ទាន់ ឬមធ្យោបាយធ្វើដំណើរដែលមានសុវត្ថិភាពទេ។

**តើខ្ញុំអាចប្រើមធ្យោបាយធ្វើដំណើរវេជ្ជសាស្ត្រដែលមិនបន្ទាន់ទៅកាន់ការណាត់ជួបទទួលវ៉ាក់សាំង COVID-19 បានដែរឬទេ?**
បាទ/ចាស យើងរ៉ាប់រងលើមធ្យោបាយធ្វើដំណើរទៅមកកន្លែងផ្តល់វ៉ាក់សាំងណាមួយ រួមមានឱសថស្ថាន គ្លីនិកចាក់វ៉ាក់សាំងទ្រង់ទ្រាយធំ និងគ្លីនិកដែលអាចបើកបរចូលបាន។ សូមទូរសព្ទទៅកាន់ឈ្មួញកណ្ដាលផ្នែកមធ្យោបាយធ្វើដំណើរក្នុងខោនធីរបស់អ្នក។ ពួកគេនឹងរៀបចំការធ្វើដំណើរមួយដែលសមស្របនឹងតម្រូវការចល័តរបស់អ្នក។

**តើនរណាអាចប្រើមធ្យោបាយធ្វើដំណើរវេជ្ជសាស្ត្រដែលមិនបន្ទាន់បាន?**
អតិថិជនរបស់ Apple Health (Medicaid) ដែលត្រូវការជំនួយមធ្យោបាយធ្វើដំណើរមានសិទ្ធិទទួលបានសេវាកម្មនេះ។

បានធ្វើបច្ចុប្បន្នភាព 1/5/21

**តើខ្ញុំត្រូវទូរសព្ទទៅនរណាសម្រាប់មធ្យោបាយធ្វើដំណើរវេជ្ជសាស្ត្រ?**
ទូរសព្ទទៅកាន់ឈ្មួញកណ្តាលផ្នែកមធ្យោបាយធ្វើដំណើរដែលបម្រើដល់ខោនធីរបស់អ្នក។ ពួកគេនឹងពិនិត្យមើលសិទ្ធិរបស់អ្នក និងសម្របសម្រួលការធ្វើដំណើររបស់អ្នក។ ប្រសិនបើអ្នកមិនមានសិទ្ធិទទួលបានសេវាកម្មនេះទេ ពួកគេនឹងបញ្ជូនអ្នកទៅធនធានក្នុងតំបន់ផ្សេងទៀត។

**តើខ្ញុំគួរទូរសព្ទទៅស្នើសុំមធ្យោបាយធ្វើដំណើរនៅពេលណា?**
អ្នកគួរតែទូរសព្ទទៅឲ្យបានឆាប់តាមដែលអ្នកអាចធ្វើបានយ៉ាងហោចណាស់ពីរថ្ងៃនៃថ្ងៃធ្វើការមុនពេលការណាត់ជួបវេជ្ជសាស្ត្ររបស់អ្នក។ ការធ្វើដំណើរបន្ទាន់ដោយមានការជូនដំណឹងតិចជាងពីរថ្ងៃនៃថ្ងៃធ្វើការអាចធ្វើទៅបាន ប្រសិនបើធនធានមានសម្រាប់ផ្តល់ជូន។

## ការទំនាក់ទំនងឈ្មួញកណ្តាល

| ឈ្មោះរបស់ឈ្មួញកណ្តាល | ខោនធីដែលបម្រើសេវាជូន | លេខទូរសព្ទ |
|---|---|---|
| **Hopelink** | King, Snohomish | 1-800-923-7433 |
| **Northwest Regional Council** | Island, San Juan, Skagit, Whatcom | 1-800-860-6812 |
| **Paratransit Services** | Clallam, Grays Harbor, Jefferson, Kitsap, Lewis, Mason, Pacific, Pierce, Thurston | 1-800-846-5438 |
| **Human Services Council** | Clark, Cowlitz, Klickitat, Skamania, Wahkiakum | 1-800-752-9422 (ជម្រើសទី 2) |
| **People for People** | Benton, Chelan, Columbia, Douglas, Franklin, Kittitas, Okanogan, Walla Walla, Yakima | 1-800-233-1624 |
| **Special Mobility Services** | Adams, Asotin, Ferry, Garfield, Grant, Lincoln, Pend Oreille, Spokane, Stevens, Whitman | 1-800-892-4817 |

សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់គេហទំព័ររបស់ Nonemergency Medical Transportation (NEMT, មធ្យោបាយធ្វើដំណើរវេជ្ជសាស្ត្រដែលមិនបន្ទាន់) hca.wa.gov/transportation-help។

**820-NonDOH May 2021 Khmer**

ដើម្បីស្នើសុំឯកសារនេះជាទម្រង់ផ្សេងទៀត សូមទូរសព្ទទៅលេខ 1-800-525-0127។ អតិថិជនដែលស្តាប់មិនឮ ឬស្តាប់មិនសូវឮ សូមទូរសព្ទទៅលេខ 711 (Washington Relay) ឬអ៊ីម៉ែល civil.rights@doh.wa.gov។

Washington State Department of Health